# ខ្មែរ -ជំនួយផ្នែកភាសាសម្រាប់ អ្នកបោះឆ្នោតនៅខោនធី Santa Clara

**<u>បោះឆ្នោតពីផ្ទះ</u>**

នៅមុនថ្ងៃបោះឆ្នោត អ្នកអាចទទួលបានឯកសារផ្សេងៗដែលបានបកប្រែហើយតាមរយៈសំបុត្រ។
ដើម្បីទទួលបានឯកសារដែលបានបកប្រែហើយ សូមធ្វើបច្ចុប្បន្នភាពអំពីចំណូលចិត្តផ្នែកភាសារបស់អ្នកនៅលើវិបសាយ
https://voterstatus.sos.ca.gov ឬទូរស័ព្ទទៅការិយាល័យបោះឆ្នោត (866-430-8683)។

ប្រសិនបើអ្នកចូលចិត្តបោះឆ្នោតជា**ភាសាខ្មែរ** នោះអ្នកអាចស្នើសុំទទួលសន្លឹកឆ្នោតដែលបានបកប្រែហើយតាមរយៈសំបុត្របាន។
ប្រសិនបើអ្នកមិនទទួលបានសន្លឹកឆ្នោត ឬឯកសារជាភាសាដែលអ្នកចង់បានទេ សូមទូរស័ព្ទទៅការិយាល័យបោះឆ្នោត។

**<u>ការបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់</u>**

បើអ្នកទៅបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅឯមណ្ឌលបោះឆ្នោត នោះអ្នកអាចប្រើជំនួយផ្ទាល់មាត់បាន។
អ្នកក៏អាច**នាំមនុស្សរហូតដល់ទៅពីរនាក់ដើម្បីជួយអ្នកធ្វើការបោះឆ្នោតបាន** ឲ្យតែអ្នកទាំងនោះមិនតំណាងឲ្យនិយោជក
ឬសហជីពរបស់អ្នក។ ឲ្យសមាជិកគ្រួសារ ឬមិត្តភក្តិជួយបាន!

ប្រសិនបើមានមន្ត្រីរៀបចំការបោះឆ្នោតដែលនិយាយពីរភាសានៅឯមណ្ឌលបោះឆ្នោតរបស់អ្នក **នោះពួកគេនឹងពាក់ស្លាកសម្គាល់ខៀវបូ ឬស្លាកស្អិត** ប្រាប់ឲ្យដឹងអំពីភាសាដែលពួកគេនិយាយ។

**ប្រសិនបើអ្នកទៅបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅឯមណ្ឌលបោះឆ្នោត**
**អ្នកអាចប្រើឯកសារបោះឆ្នោតដែលបានបកប្រែជាភាសាខ្មែរហើយ រួមទាំងសន្លឹកឆ្នោតដែលអ្នកអាចបោះឆ្នោតបាន។**
វានឹងមាននៅគ្រប់មណ្ឌលបោះឆ្នោត។ នៅពេលអ្នកកំពុងចុះឈ្មោះចូលបោះឆ្នោត
អ្នកគ្រាន់តែឲ្យបុគ្គលិកនៅមណ្ឌលបោះឆ្នោតដឹងថា អ្នកចង់បានសន្លឹកឆ្នោតជាភាសាខ្មែរ នោះពួកគេនឹងផ្តល់ឲ្យអ្នកហើយ។

**ប្រសិនបើអ្នកមានបញ្ហាអ្វីមួយនៅពេលបោះឆ្នោត សូមទាក់ទងការិយាល័យបោះឆ្នោតខោនធីតាមលេខ 866-430-8683 ឬទាក់ទងទៅ 888-API-VOTE (888-274-8683) ដើម្បីសុំជំនួយ។**